**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងព្រហ្មទណ្ឌលេខ៖ **១២៧៥ អក**

**ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១**

សាលក្រមព្រហ្មទណ្ឌលេខ: **១១៤ "ឌ"**

**ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២**

# សាលក្រមព្រហ្មទណ្ឌ

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តកណ្តាល នាថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ០៩៖៣០ នាទីព្រឹក ដោយមានសមាសភាពចូលរួមដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តកណ្តាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល

**មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី**

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុង** ។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ**

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **វឌ្ឍា** ។

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ៖ **១២៧៥ អ.ក** ចុះថ្ងៃទី០៩ **ខែសីហា ឆ្នាំ២០២១** ដែលមានជនជាប់ចោទឈ្មោះ [redacted] **វឌ្ឍា** ភេទប្រុស អាយុ ៣៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ លក់ដូរ មានទីកន្លែងកំណើតភូមិ [redacted] ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្នភូមិព្រែកបង្កង ឃុំព្រែកតាកូវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] **ញឹម (ស្លាប់)** ម្តាយឈ្មោះ [redacted] **យ៉ន (ស្លាប់)** ប្រពន្ធឈ្មោះ [redacted] **វតនា** មានកូនចំនួន ០៣នាក់។ (ក្រៅឃុំ)

ជាប់ចោទពីបទ ៖ **ឆបោក** ប្រព្រឹត្តនៅភូមិព្រែកក្របៅទី៣ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា**៣៧៧** និងមាត្រា **៣៧៨** នៃក្រមព្រហ្មទណ្ឌ ។

[redacted]

- **បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ **៣៦២ ដកសស/២២** ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល។
- **បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ៖ **៨២៥ ដក.សព/២២** ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល។
- **បានឃើញ** ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ **៤៥២ ដកជរ** ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល។
- **បានឃើញ** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ៖**៩៨៦ ដកចត/២២** ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តកណ្តាល។

**អង្គហេតុដែលប្តឹងមកតុលាការមានដូចតទៅ៖**

កាលនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ ឈ្មោះ [redacted] **សុង** បានចុះកិច្ចសន្យាលក់-ទិញ អចលនវត្ថុ ជាមួយឈ្មោះ [redacted] **វង្សា** លើដីចំនួន២កន្លែង ទំហំ **២០,០០០ ម៉ែត្រការ៉េ** សរុបជាទឹកប្រាក់ចំនួន **៤២០,០០០ (សែសិបពីរម៉ឺន) ដុល្លារ** ដែលមានទីតាំងស្ថិតនៅភូមិព្រែកក្របៅ៣ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដោយមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ: **០០៩/១២ ពអព** ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ **០១០/១២ ពអព** ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ របស់រដ្ឋបាលឃុំព្រែកអំពិល និងមានការទទួលស្គាល់ដោយគណៈកម្មការត្រួតពិនិត្យដីធ្លីភូមិក្របៅ ។ ក្រោយចុះកិច្ចព្រមព្រៀងនេះរួចមក ឈ្មោះ [redacted] **វង្សា** មិនបានផ្ទេរសិទ្ធិដីខាងលើឲ្យទៅឈ្មោះ [redacted] **សុង** ដោយមានលេសមិនចេះចប់ និងពន្យាពេលរហូត ដោយមិនបានបំពេញកាតព្វកិច្ចក្នុងការចូលរួមនីតិវិធីសុរិយោដីឡើយ ។ ក្រោយពីការរកឃើញភាពមិនប្រក្រតីត្រង់ចំណុចអាយុរបស់ឈ្មោះ [redacted] **វង្សា** ដូចជាលិខិតផ្ទេរសិទ្ធកាន់កាប់ប្រើប្រាស់ដីធ្លីលេខ: **០១០/១២ ពអព** ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ ផ្ទៃក្រឡា **៣៤,០២៩ ម៉ែត្រការ៉េ** រីឯពាក្យសុំផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខ **៤៩៦ អព** ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ ផ្ទៃក្រឡា **៣៤០២.៩ ម៉ែត្រការ៉េ** ក្រោយមកឈ្មោះ [redacted] **សុង** បានព្យាយាមទាក់ទងទៅឈ្មោះ [redacted] **វង្សា** ដើម្បីដោះស្រាយ តែមិនមានដំណោះស្រាយ ទើបសម្រេចដាក់ពាក្យបណ្តឹងឈ្មោះ [redacted] **វង្សា** តែម្តង ។

**នាពេលសវនាការ**

១- ជនជាប់ចោទឈ្មោះ [redacted] **វង្សា** អវត្តមាននៅពេលសវនាការ ។

**២**-តាមអំណានចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] **សុង** បានឆ្លើយថា៖ ខ្លួនស្គាល់ឈ្មោះ [redacted] **វង្សា** រយៈពេល ០៤ឆ្នាំ មកហើយ ស្គាល់តាមរយៈអ្នកគួកជេរដី ហើយឈ្មោះ [redacted] **វង្សា** ធ្លាប់ខ្ចីប្រាក់ពីខ្លួនចំនួន **៣៥០,០០០ (សាមសិបប្រាំម៉ឺន) ដុល្លាអាមេរិក** ដោយខ្ចីដើម្បីយកទៅពង្រីកមុខរបររបស់គាត់ ហើយក្រោយមកគាត់សងបានចំនួន **៣០,០០០ (បីម៉ឺន) ដុល្លាអាមេរិក** ។ ក្រោយមកដោយឈ្មោះ [redacted] **វង្សា** មានបំណងដោះដូរដី និងកាត់សងបំណុលរបស់គាត់ដែលបានជំពាក់ប្រាក់ខ្លួន ហើយសុំខ្លួនខ្ចីបន្ថែម **២០,០០០(ពីរម៉ឺន) ដុល្លាអាមេរិក** ដោយអះអាងថា យកទៅរត់ប្លង់ដីចំនួន ០២ កន្លែង ដែលគាត់ចង់លក់ដោះដូរប្រាក់ដែលជំពាក់

ឱ្យខ្លួន ។ កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ ខ្លួន និងឈ្មោះ [redacted] វង្សា បានព្រមព្រៀងគ្នាទិញលក់ដីចំនួន ០២ កន្លែង មានទំហំ០២ ហិចតា ក្នុងតម្លៃ ៤២០,០០០ (សែសិបពីរម៉ឺន) ដុល្លារអាមេរិក មានទីតាំងនៅភូមិព្រៃកក្របៅទី៣ ឃុំព្រៃកអំពិល ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ដោយដីទី១ មានទំហំ ៣៤,០២៩ ម៉ែត្រការ៉េ (បីម៉ឺនបួនពាន់ម្ភៃប្រាំបួន) ម៉ែត្រការ៉េ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី លេខ ០១០/២២ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ ដោយមានហត្ថលេខាមេឃុំព្រៃកអំពិលដែរ។ ក្នុងការទិញលក់នេះពួកខ្លួនទាំងពីរនាក់បានធ្វើកិច្ចព្រមព្រៀងលក់ទិញដី ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ ដោយទិញលក់ ក្នុងទំហំដីតែ ០២ ហិកតា នៃទំហំ ៣៤,០២៩ (បីម៉ឺនបួនពាន់ម្ភៃប្រាំបួន) ម៉ែត្រការ៉េ តែប៉ុណ្ណោះ ដោយឈ្មោះ [redacted] វង្សា បានព្រមព្រៀងក្នុងការផ្ទេរកម្មសិទ្ធិដីនេះឱ្យរួចរាល់នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ ទើបខ្លួនយល់ព្រមបង់ប្រាក់បង្គ្រប់ចំនួន [redacted]០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក បន្ថែមទៀត ។ មុនពេលទិញ និងក្រោយពេលទិញខ្លួនបានចុះទៅមើលទី[redacted]ងដីនោះដែរដោយទៅជាមួយនឹងកូនចៅរបស់ឈ្មោះ [redacted] វង្សា តែឈ្មោះ [redacted] វង្សា មិនបានទៅជាមួយនឹង[redacted]នោះទេ ។ ក្រោយពេលទិញលក់ជាមួយនឹងឈ្មោះ [redacted] វង្សា បានដាក់ពាក្យស្នើសុំផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជី ហើយខាងស្រុកបានជូនដំណឹងឱ្យចូលរួមក្នុងការវាស់វែងនោះដែរ តែឈ្មោះ [redacted] វង្សា មិនបានចូលរួមនោះទេ មានតែកូនចៅរបស់គាត់ប៉ុណ្ណោះ ដែលទៅចូលរួមក្នុងការវាស់នោះ ហើយខ្លួនបានទៅចូលរួមជាមួយនឹងខាងអាជ្ញាធរ ។ លុះពេលចុះវាស់វែងហើយមួយខែក្រោយមកស្រាប់តែខាងសាលាស្រុកចេញរបាយការណ៍ជូនដំណឹងដោយបញ្ជាក់ថាដីនេះជាដីអូរ ។ ចំពោះលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ០០៩/១២ ពអព ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ ដោយមានហត្ថលេខាមេឃុំព្រៃកអំពិល ពិនិត្យឃើញថា ពេលធ្វើកិច្ចសន្យាទិញលក់នៅឆ្នាំ២០១២ ឃើញថាមានការខុសអាយុរបស់ឈ្មោះ [redacted] វង្សា ដោយដាក់ថា ៣២ឆ្នាំ តែជាក់ស្ដែងឈ្មោះ [redacted] វង្សា អាយុ ២៥ឆ្នាំ នៅឆ្នាំ២០១២ ។ ចំពោះលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី លេខ ០១០/១២ ចុះថ្ងទី១២ ខែមករា ឆ្នាំ២០១២ ដោយមានហត្ថលេខាមេឃុំព្រៃកអំពិល ឃើញថា មានការចុះខុសទំហំដី ៣៤០២.៩ ម៉ែត្រការ៉េ តែក្នុងកិច្ចព្រមព្រៀងលក់ទិញដីដាក់ទំហំ ៣៤,០២៩ ម៉ែត្រការ៉េ ហើយចំពោះអ្នកផ្ទេរសិទ្ធិឈ្មោះ [redacted] ឡឹក និងឈ្មោះ [redacted] គុន ជាឈ្មោះខ្មោច ហើយមានភាពមិនប្រក្រតីត្រង់ថាប្ដីរបស់ឈ្មោះ [redacted] គុន មានឈ្មោះ ចន មិនមែនឈ្មោះ [redacted] ឡឹក នោះទេ ។ ខ្លួនមានឯកសារដូចជា កិច្ចព្រមព្រៀងបញ្ចប់វិវាទ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ កិច្ចព្រមព្រៀង លក់ទិញដី ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០, លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ០០៩/១២ ពអព ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២, លិខិតអះអាង ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២, សៀវភៅស្នាក់នៅលេខ ០១១ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៩៩ ពាក្យស្នើសុំផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខ ៤៩៤ ពអព ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ និង កំណត់ហេតុពិភាក្សា ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២១ ។

+ **មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីបានធ្វើសេចក្ដីសន្និដ្ឋានថា** ផ្អែកតាមអង្គហេតុ និង អង្គច្បាប់ ឃើញថា ឈ្មោះ [redacted] វង្សា ពិតជាមានចេតនាក្នុងការបោកប្រាស់ប្រាក់កូនក្ដីខ្ញុំ ដោយអះអាងថា ខ្លួនពិតជាម្ចាស់កម្មសិទ្ធិលើដីទំហំ ៣៤,០២៩ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិព្រៃកក្របៅ៣ ឃុំព្រៃកអំពិល ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ពិតប្រាកដមែន ប៉ុន្តែជាក់ស្ដែងនៅក្នុងនេះពុំមែនជាម្ចាស់កម្មសិទ្ធិ

លើដីទំហំនេះឡើយ ពីព្រោះពាក់ព័ន្ធនិងអង្គហេតុនេះវាកើតឡើងតាំងពីឆ្នាំ២០១៩ ដែលធ្វើឱ្យកូនក្តីខ្លួនចាញ់បោកឧបាយកលទុច្ចរិត និងខាតបង់ទឹកប្រាក់អស់ចំនួន **៣៤ ម៉ឺនដុល្លាអាមេរិក** ដោយសារការឆបោកនេះ កូនក្តីខ្ញុំរង់ចាំការផ្ទេរសិទ្ធិដីខាងលើនេះមកខ្លួន រហូតដល់ការមានការជូនដំណឹងជាច្រើនលើកច្រើនសារ និងការពន្យាពេល គេចវេស ម្តងហើយម្តងទៀតរបស់ឈ្មោះ [redacted] **វង្សា** រហូតដល់មានកំណត់ហេតុការសន្យា ផ្ទេរសិទ្ធិដីមានការកំណត់ និងកិច្ចព្រមព្រៀងបញ្ចប់វិវាទជាបន្តបន្ទាប់ ។ ជាក់ស្តែងឈ្មោះ [redacted] **វង្សា** នៅតែមិនអាចផ្ទេរកម្មសិទ្ធិដីបាន និងមិនអាចចង្អុលបង្ហាញពីទីតាំងដីពិតប្រាកដឡើយ ដែលសកម្មភាពទាំងអស់នេះបានស្តែងឱ្យឃើញថា ការប្រើប្រាស់ឧបាយកលទុចរិតក្នុងការរៀបចំឯកសារក្លែងក្លាយ និងប្រើឈ្មោះអ្នក[redacted]ទ ដែលសកម្មភាពទាំងអស់នេះ គឺស្តែងពីការឆបោកកូនក្តីខ្ញុំ ហេតុដូច្នេះស្នើសុំឱ្យតុលាការចាប់ឃុំខ្លួន និង[redacted]ទោសឈ្មោះ [redacted] **វង្សា** ពីបទឆបោក តាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ហើយបង្គាប់ឱ្យឈ្មោះ [redacted] **វង្សា** សងប្រាក់ចំនួន **៣៤ ម៉ឺនដុល្លារអាមេរិក** មកឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងសុំទាមទារសំណងជម្ងឺចិត្ត និងសេវាកម្មផ្លូវច្បាប់ចំនួន **១០ ម៉ឺនដុល្លារអាមេរិក** ។

+ **តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖** នៅពេលសវនាការជនជាប់ចោទពុំមានវត្តមាននៅក្នុងសវនាការទេ ហើយចៅក្រមស៊ើបសួរក៏បានចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទផងដែរ។ តាមអង្គហេតុដែលបានកើតឡើង និងភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឃើញថាជនជាប់ចោទឈ្មោះ [redacted] **វង្សា** ពិតជាបានប្រព្រឹត្តបទឆបោក ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុង** ប្រាកដមែន ដូច្នេះតំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងសុំលោកចៅក្រមពិនិត្យសម្រេចតាមច្បាប់ ។

+ **មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វង្សា** បានធ្វើសេចក្តីសន្និដ្ឋានថា ៖ កូនក្តីខ្ញុំឈ្មោះ [redacted] **វង្សា** កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ កូនក្តីរបស់ខ្ញុំបាទបានចុះកិច្ចព្រមព្រៀងទិញលក់ដីមួយកន្លែង ទំហំ ១០ ហិកតា ក្នុងតម្លៃ **៣៥ ម៉ឺនដុល្លារអាមេរិក** ដែលមានទីតាំងស្ថិតនៅក្នុងភូមិព្រែកក្របៅ៣ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។ ចំពោះការទិញលក់ដីនេះកូនក្តីខ្ញុំបានទទួលប្រាក់តែចំនួន **៣ ម៉ឺនដុល្លារអាមេរិក** តែប៉ុណ្ណោះ រីឯប្រាក់ចំនួន **៣២ ម៉ឺនដុល្លារអាមេរិក** ទៀត កូនក្តីខ្ញុំបាទពុំបានទទួលដូចក្នុងពាក្យបណ្តឹងនោះឡើយ ដោយហេតុថាឈ្មោះ [redacted] សុង មិនអាចធ្វើការផ្ទេរសិទ្ធិដីចំនួន **១០ ហិកតា** នេះមកឱ្យកូនក្តីខ្ញុំបានឡើយ ដោយមានតតិយជនឈ្មោះ [redacted] **ចាន់ថន** បានដាក់ពាក្យបណ្តឹងមកស្រុកខ្សាច់កណ្តាល នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ហើយដីដែលឈ្មោះ [redacted] **សុង** លក់ឱ្យកូនក្តីខ្ញុំ ក៏កំពុងតែមានទំនាស់ផង ។ នៅក្នុងកំណត់ហេតុរបស់សាក្សីឈ្មោះ [redacted] **ជា** ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ជាមេភូមិព្រែកក្របៅ៣ បានឆ្លើយថា នៅក្នុងកំឡុងឆ្នាំ២០២១ ឈ្មោះ [redacted] **ឡឹក** និងឈ្មោះ [redacted] **តុន** ពិតបានលក់ដីឱ្យឈ្មោះ [redacted] **វង្សា** ទំហំ **៣៤,០២៩ ម៉ែត្រការ៉េ** ដែលទីតាំងស្ថិតនៅភូមិព្រែកក្របៅ៣ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដូចក្នុងកិច្ចសន្យាទិញលក់ដី ចុះថ្ងៃទី**២៣** ខែមេសា ឆ្នាំ**២០២០** ក្រោយមកឈ្មោះ [redacted] **វង្សា** បានលក់ដីនោះទៅឱ្យឈ្មោះ [redacted] សុង ទំហំ ៣៤,០២៩ **ម៉ែត្រការ៉េ** ដែលទីតាំងស្ថិតនៅភូមិព្រែកក្របៅ៣ ឃុំព្រែកអំពិល ស្រុក ខ្សាច់កណ្តាល ខេត្តកណ្តាល ។ ភស្តុតាងដែលកូនក្តីខ្ញុំមាន គឺលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ៖ **០០៩/១២ ព**

**អព** ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ ដែលបញ្ជាក់ថាកូនក្តីខ្ញុំពិតជាមានដីពិតប្រាកដមែន និងលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ០១០/១២ **ពអព** ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ ។ ដោយផ្អែកលើអង្គច្បាប់ និងធាតុផ្សំបទល្មើសព្រហ្មទណ្ឌដាច់ខាត គឺផ្អែកលើធាតុផ្សំទាំងបីគឺ ធាតុនីត្យានុកូល ,ធាតុសត្យានុម័ត និងធាតុអត្តនោម័ត ប៉ុន្តែផ្ទុយទៅនឹងការចោទប្រកាន់លើកូនក្តីខ្ញុំ គឺពុំមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ ដែលអាចចោទប្រកាន់បទល្មើសព្រហ្មទណ្ឌបានឡើយ ដោយហេតុថាអង្គហេតុរបស់កូនក្តីខ្ញុំ និងដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ[redacted]សុង គឺជាវិវាទកិច្ចសន្យាទិញលក់ដី ដែលជារឿងក្តីរដ្ឋប្បវេណីប៉ុណ្ណោះ។ បើយោងតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញបានចែងថា "**វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ**" និងមាត្រា ៣៥១ នៃក្រមព្រហ្មទណ្ឌ ដូចេ្នះក្នុងនាមខ្ញុំជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted] **វង្គា** ស្នើសុំឱ្យតុលាការមេត្តាលើកលែងបទ[redacted]ដល់កូនក្តីខ្ញុំបាទតាមច្បាប់ជាធរមាន ។

## សាលាដំបូងខេត្តកណ្តាល យល់ឃើញថា

១-កាលនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ ឈ្មោះ [redacted]**សុង** បានចុះកិច្ចសន្យាលក់-ទិញ អចលនវត្ថុ ជាមួយឈ្មោះ[redacted] **វង្គា** លើដីចំនួន២កន្លែង ទំហំ **២០,០០០ ម៉ែត្រការ៉េ** សរុបជាទឹកប្រាក់ចំនួន **៤២០,០០០ (សែសិបពីរម៉ឺន) ដុល្លារ** ដែលមានទីតាំងស្ថិតនៅភូមិព្រៃកក្របៅ៣ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដោយមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខៈ **០០៩/១២ ពអព** ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ និងលិខិតយផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ **០១០/១២ ពអព** ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ របស់រដ្ឋបាលឃុំព្រែកអំពិល និងមានការទទួលស្គាល់ដោយគណៈកម្មការត្រួតពិនិត្យដីធ្លីភូមិក្របៅ ។ ក្រោយចុះកិច្ចព្រមព្រៀងនេះរួចមក ឈ្មោះ[redacted]**ង្គា** មិនបានផ្ទេរសិទ្ធិដីខាងលើឱ្យទៅឈ្មោះ[redacted]**សុង** ដោយមានលេសមិនចេះចប់ និងពន្យាពេលរហូត ដោយមិនបានបំពេញកាតព្វកិច្ចក្នុងការចូលរួមនីតិវិធីសុរិយោដីឡើយ ។ ក្រោយពីការរកឃើញភាពមិនប្រក្រតីត្រង់ចំណុចអាយុរបស់ឈ្មោះ [redacted] **វង្គា** ដូចជាលិខិតផ្ទេរសិទ្ធកាន់កាប់ប្រើប្រាស់ដីធ្លីលេខៈ **០១០/១២ ពអព** ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ ផ្ទៃក្រឡា **៣៤,០២៩ ម៉ែត្រការ៉េ** រីឯពាក្យសុំផ្ទេរសិទ្ធិកានកាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខ **៤៩៦ អព** ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០២១ ផ្ទៃក្រឡា **៣៤០២.៩ ម៉ែត្រការ៉េ** ក្រោយមកឈ្មោះ[redacted]**សុង** បានព្យាយាមទាក់ទងទៅឈ្មោះ[redacted]**វង្គា** ដើម្បីដោះស្រាយ តែមិនមានដំណោះស្រាយ ទើបសម្រេចដាក់ពាក្យបណ្តឹងឈ្មោះ[redacted] **វង្គា** តែម្តង ។

២-ជនជាប់ចោទឈ្មោះ[redacted] **វង្គា** ជានីតិជនមានសមត្ថភាព និងមានលក្ខណៈសម្បត្តិល្អគ្រប់គ្រាន់ដែលអាចដឹង និងទទួលខុសត្រូវនូវអំពើប្រព្រឹត្តរបស់ខ្លួនបាន ។

៣- តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ធៀបនឹងឯកសារភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង ឃើញថា ជនជាន់ចោទឈ្មោះ[redacted] **វង្គា** ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន ។

៤-មានពិរុទ្ធភាពគ្រប់គ្រាន់ ដើម្បីដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] **វង្គា** ភេទប្រុស អាយុ ៣៧ឆ្នាំ ពីបទ៖ **ឆបោក** ប្រព្រឹត្តនៅចំណុចភូមិព្រៃក្របៅទី៣ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៣៧៧ និងមាត្រា ៣៧៨** នៃក្រមព្រហ្មទណ្ឌ ។

៥- ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា ពុំបានចូលមកឆ្លើយបំភ្លឺគ្រប់ដំណាក់កាលនៃការស៊ើបសួរ ដូច្នេះ ឃើញថា ជនជាប់ចោទមានចេតនាទុច្ចរិតក្នុងការគេចវេសមិនទទួលខុសត្រូវនូវការប្រព្រឹត្តរបស់ខ្លួន ហើយ ដើម្បីជាការអនុវត្តច្បាប់ឱ្យបានពេញលេញ តុលាការគប្បីចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] រដ្ឋា ស្របតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៦-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុង បានទាមទារប្រាក់ដែលបាត់បង់ចំនួន ៣៤០,០០០ **(សាមសិបបួនម៉ឺន)ដុល្លារអាមេរិក** និងសំណងជម្ងឺចិត្តចំនួន ១០០,០០០ **(ដប់ម៉ឺន) ដុល្លារអាមេរិក** ពីជនជាប់ចោទឈ្មោះ [redacted] សុង គប្បីតុលាការពិនិត្យសម្រេចស្របតាមមាត្រា ១៣ និងមាត្រា ១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

## ហេតុដូច្នេះសម្រេច

**១-ផ្តន្ទាទោស** ÷ ជនជាប់ចោទ ឈ្មោះ [redacted] រដ្ឋា ភេទប្រុស អាយុ ៣៧ឆ្នាំ (អត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល០១ **ឆ្នាំ និង ០៦ ខែ (មួយឆ្នាំ និងប្រាំមួយខែ)** ពីបទ៖ **ឆបោក** ប្រព្រឹត្តនៅចំណុចភូមិព្រៃក្របៅទី៣ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៧៧ និងមាត្រា ៣៧៨** នៃក្រមព្រហ្មទណ្ឌ ។

២- បង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] **រដ្ឋា** ភេទប្រុស អាយុ ៣៧ឆ្នាំ តាមបញ្ញត្តិមាត្រា **៣៥៣** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣- បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] **រដ្ឋា** ភេទប្រុស អាយុ ៣៧ឆ្នាំ សងប្រាក់ដែលបាត់បង់ចំនួន ៣៤០,០០០**(សាមសិបបួនម៉ឺន)ដុល្លារអាមេរិក** និងសំណងជម្ងឺចិត្តចំនួន ៣០,០០០**(បីម៉ឺន) ដុល្លារអាមេរិក** ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុង ។ ការទាមទារលើសពីនេះត្រូវច្រានចោល ។

សាលក្រមនេះ ជំនុំជម្រះ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៥ ខែតុលាឆ្នាំ២០២២ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] រដ្ឋា តែចាត់ទុកថាចំពោះមុខ នឹងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុង ។

***ទុកសិទ្ធិប្តឹងទាស់ ឬ ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។***

**ក្រឡាបញ្ជីសវនាការ**

[redacted]

**ចៅក្រមជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

កណ្តាល. ថ្ងៃទី 20 ខែ[illegible] ឆ្នាំ 20..23

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner